BỘ TƯ PHÁP | CHÍNH PHỦ NHẬT BẢN | QUỸ PHÁT TRIỂN XÃ HỘI NHẬT BẢN | NGÂN HÀNG THẾ GIỚI

ជំនួយគតិយុត្តិក្នុងការចុះបញ្ជីអាពាហ៍ពិពាហ៍



ឆ្នាំ ២០២៥.

តើជំនួយគតិយុត្តិជាអ្វី?

ជំនួយគតិយុត្តិ គឺជាការផ្តល់សេវាគតិយុត្តិដោយឥតគិតថ្លៃ ជូនអ្នកទទួលបានជំនួយគតិយុត្តិ ក្នុងរឿងក្តីជំនួយគតិយុត្តិ ស្រប តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជំនួយគតិយុត្តិ។

អ្នកដែលស្ថិតក្នុងចំណោមអ្នកទទួលបានជំនួយគតិយុត្តិ រួមមាន៖

- អ្នកមានគុណបំណាច់ចំពោះបដិវត្តន៍។
- អ្នកស្ថិតក្នុងគ្រួសារក្រីក្រ។
- កុមារ។
- ជនជាតិភាគតិចដែលរស់នៅតំបន់មានលក្ខខណ្ឌសេដ្ឋកិច្ច-សង្គមលំបាកជាពិសេស។
- អ្នកមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ៖ គឺជាអ្នកត្រូវបានចោទប្រកាន់ អ្នកត្រូវបានស្នើសុំឲ្យចោទប្រកាន់ អ្នកត្រូវបានឃាត់ខ្លួនក្នុងករណីបន្ទាន់ អ្នកជាប់ចោទ ជនរងគ្រោះ សាក្សី អ្នកអនុវត្តវិធានការដោះស្រាយបែបបង្វែរទិស និងទណ្ឌិត (អនុវត្តចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០២៦)។
- អ្នកចុងចោទដែលស្ថិតក្នុងគ្រួសារបៀតក្រីក្រ។
- ជនរងគ្រោះ អ្នកកំពុងស្ថិតក្នុងដំណើរការបញ្ជាក់ថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងអ្នកអាយុក្រោម ១៨ ឆ្នាំដែលទៅជាមួយ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការទប់ស្កាត់ និងប្រឆាំងការជួញដូរមនុស្ស។
- អ្នកស្ថិតក្នុងករណីណាមួយដូចខាងក្រោម ដែលមានការលំបាកផ្នែកហិរញ្ញវត្ថុ៖
- ឪពុកបង្កើត ម្តាយបង្កើត ភរិយា ស្វាមី កូនរបស់យុទ្ធជនពលី និងអ្នកមានគុណបំណាច់ចិញ្ចឹមបីបាច់យុទ្ធជនពលីកាលនៅតូច។
- អ្នកឆ្លងជាតិពុលពណ៌ទឹកក្រូច (ដាយអុកស៊ីន)។
- មនុស្សចាស់។
- ជនពិការ។
- អ្នកមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលជាជនរងគ្រោះក្នុងរឿងក្តីព្រហ្មទណ្ឌ។
- ជនរងគ្រោះក្នុងរឿងក្តីអំពើហិង្សាក្នុងគ្រួសារ។
- អ្នកផ្ទុកមេរោគអេដស៍ (HIV)។



- ពាក្យស្នើសុំជំនួយគតិយុត្តិ។
- លិខិតស្នាមបញ្ជាក់ថាជាអ្នកទទួលបានជំនួយគតិយុត្តិ។
- លិខិតស្នាម និងឯកសារនានាដែលពាក់ព័ន្ធនឹងរឿងក្តី។

អាសយដ្ឋានទំនាក់ទំនងដើម្បីស្នើសុំជំនួយគតិយុត្តិ៖

- មជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ ក្រោមឱវាទមន្ទីរយុត្តិធម៌ខេត្ត និងក្រុង ក្រោមឱវាទថ្នាក់កណ្តាល។
- អង្គការប្រកបវិជ្ជាជីវៈមេធាវី និងអង្គការប្រឹក្សាច្បាប់ ដែលចូលរួមជំនួយគតិយុត្តិ។
- អាសយដ្ឋានរបស់អង្គការអនុវត្តជំនួយគតិយុត្តិដែលបានរៀបរាប់ខាងលើ ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅ៖
- គេហទំព័រនីតិកម្មជាតិ *(https://phapluat.gov.vn/)*
- គេហទំព័រព័ត៌មានអេឡិចត្រូនិកក្រសួងយុត្តិធម៌ *(https://dstrogiupphaply.moj.gov.vn/all/searchOrganization)*។
- គេហទំព័រព័ត៌មានអេឡិចត្រូនិកជំនួយគតិយុត្តិវៀតណាម *(https://tgpl.moj.gov.vn/Pages/danh-ba-phap-ly.aspx)*។
- គេហទំព័រព័ត៌មានអេឡិចត្រូនិកមន្ទីរយុត្តិធម៌។
- លោកអ្នកអាចទាក់ទងតាមបណ្តាញដូចខាងក្រោម ដើម្បីដឹងព័ត៌មានបន្ថែមអំពីជំនួយគតិយុត្តិ៖
- ខ្សែទូរស័ព្ទទាន់ហេតុការណ៍អំពីជំនួយគតិយុត្តិ៖ *18001233/02462739631*
- ទាញយកកម្មវិធីទូរស័ព្ទចល័តអំពីជំនួយគតិយុត្តិ។

លក្ខខណ្ឌនៃការចុះបញ្ជីអាពាហ៍ពិពាហ៍
(កំណត់នៅមាត្រា ៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ)

- បុរសមានអាយុពេញ ២០ ឆ្នាំឡើងទៅ ស្ត្រីមានអាយុពេញ ១៨ ឆ្នាំឡើងទៅ។
- ការរៀបអាពាហ៍ពិពាហ៍ គឺដោយបុរស និងស្ត្រីសម្រេចដោយស្ម័គ្រចិត្ត។
- ភាគីទាំងសងខាង មិនបាត់បង់សមត្ថភាពទង្វើរដ្ឋប្បវេណី។
- មិនស្ថិតក្នុងករណីណាមួយនៃការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍។

សំណុំឯកសារចុះបញ្ជីអាពាហ៍ពិពាហ៍៖

- តាមមាត្រា ១៨ នៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០១៤ បានកំណត់ថា នៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ ភាគីទាំងពីរ បុរស និងស្ត្រី ត្រូវរៀបចំលិខិតស្នាមដូចខាងក្រោម៖
- សន្លឹកប្រកាសចុះបញ្ជីអាពាហ៍ពិពាហ៍តាមទម្រង់ដែលមានព័ត៌មានគ្រប់គ្រាន់របស់ភាគីទាំងពីរ បុរស និងស្ត្រី។ ភាគីទាំងពីរ បុរស និងស្ត្រី អាចប្រកាសរួមគ្នាក្នុងសន្លឹកប្រកាសចុះបញ្ជីអាពាហ៍ពិពាហ៍តែមួយ (បើអ្នកស្នើសុំជ្រើសរើសដាក់ស្នើសំណុំឯកសារតាមទម្រង់ដោយផ្ទាល់)។
- ទម្រង់អត្រានុកូលដ្ឋានអេឡិចត្រូនិកអន្តរកម្មចុះបញ្ជីអាពាហ៍ពិពាហ៍ (ដោយអ្នកស្នើសុំផ្តល់ព័ត៌មានតាមការណែនាំនៅលើគេហទំព័រសេវាសាធារណៈ បើអ្នកស្នើសុំជ្រើសរើសដាក់ស្នើសំណុំឯកសារតាមទម្រង់អនឡាញ)។

- អ្នកស្នើសុំចុះបញ្ជីអាពាហ៍ពិពាហ៍ ត្រូវអនុវត្តការដាក់ស្នើ/បង្ហាញ (តាមទម្រង់ដោយផ្ទាល់) ឬបញ្ចូល (តាមទម្រង់អនឡាញ) នូវលិខិតស្នាមដូចខាងក្រោម៖

+ លិខិតឆ្លងដែន/អត្តសញ្ញាណប័ណ្ណ/ប័ណ្ណអត្តសញ្ញាណពលរដ្ឋ/ប័ណ្ណអត្តសញ្ញាណ/អត្តសញ្ញាណអេឡិចត្រូនិក/លិខិតបញ្ជាក់អត្តសញ្ញាណ ឬលិខិតស្នាមផ្សេងទៀត ដែលមានបិទរូបថត និងព័ត៌មានផ្ទាល់ខ្លួន ចេញដោយស្ថាប័នមានសមត្ថកិច្ច ហើយនៅមានសុពលភាព។ ក្នុងករណីព័ត៌មានផ្ទាល់ខ្លួនក្នុងលិខិតស្នាមទាំងនេះ មានរួចហើយក្នុងមូលដ្ឋានទិន្នន័យជាតិស្តីពីប្រជាជន (CSDLQGVDC) និងមូលដ្ឋានទិន្នន័យអត្រានុកូលដ្ឋានអេឡិចត្រូនិក (CSDLHTĐT) ដែលប្រព័ន្ធបំពេញដោយស្វ័យប្រវត្តិ នោះមិនចាំបាច់បញ្ចូលឡើយ (តាមទម្រង់អនឡាញ)។

+ លិខិតស្នាមដែលមានតម្លៃបញ្ជាក់ព័ត៌មានអំពីទីលំនៅ ក្នុងករណីស្ថាប័នចុះបញ្ជីអត្រានុកូលដ្ឋានមិនអាចទាញយកព័ត៌មានអំពីទីលំនៅរបស់ពលរដ្ឋបាន។ ក្នុងករណីព័ត៌មានអំពីលិខិតស្នាមបញ្ជាក់ទីលំនៅ ត្រូវបានទាញយកពីមូលដ្ឋានទិន្នន័យជាតិស្តីពីប្រជាជនតាមមធ្យោបាយទាំងនេះ នោះអ្នកស្នើសុំមិនចាំបាច់បង្ហាញ (តាមទម្រង់ដោយផ្ទាល់) ឬបញ្ចូល (តាមទម្រង់អនឡាញ) ឡើយ។

ស្ថាប័នអនុវត្ត

គណៈកម្មាធិការប្រជាជនថ្នាក់ឃុំ/សង្កាត់។

លំដាប់នៃការអនុវត្ត

១. ដោយផ្ទាល់៖

អ្នកស្នើសុំចុះបញ្ជីអាពាហ៍ពិពាហ៍ អនុវត្តការដាក់ស្នើសំណុំឯកសារដោយផ្ទាល់នៅផ្នែកច្រកតែមួយ របស់គណៈកម្មាធិការប្រជាជនថ្នាក់ឃុំ/សង្កាត់ (ភាគីបុរស ឬភាគីស្ត្រី អាចដាក់ស្នើសំណុំឯកសារបានដោយមិនចាំបាច់មានលិខិតប្រគល់សិទ្ធិពីភាគីម្ខាងទៀត)។ បង់កម្រៃប្រសិនបើស្ថិតក្នុងករណីត្រូវបង់កម្រៃចុះបញ្ជីអាពាហ៍ពិពាហ៍។ បង់កម្រៃចេញច្បាប់ចម្លងសម្រង់អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ បើមានការស្នើសុំចេញច្បាប់ចម្លងសម្រង់អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍។

២. អនឡាញ៖

អ្នកស្នើសុំចុះបញ្ជីអាពាហ៍ពិពាហ៍ ដាក់ស្នើសំណុំឯកសារតាមអនឡាញនៅលើគេហទំព័រសេវាសាធារណៈជាតិ (https://dichvucong.gov.vn) (ភាគីបុរស ឬភាគីស្ត្រី អាចដាក់ស្នើសំណុំឯកសារបាន ដោយមិនចាំបាច់មានលិខិតប្រគល់សិទ្ធិពីភាគីម្ខាងទៀត)។

៣. សេវាប្រៃសណីយ៍៖

ផ្ញើសំណុំឯកសារទៅផ្នែកច្រកតែមួយ របស់គណៈកម្មាធិការប្រជាជនថ្នាក់ឃុំ/សង្កាត់ ត្រង់ទីលំនៅរបស់ភាគីបុរស ឬស្ត្រី។

រយៈពេលដោះស្រាយ

ដោយផ្ទាល់៖ ភ្លាមក្នុងថ្ងៃទទួលសំណុំឯកសារ។ ក្នុងករណីទទួលសំណុំឯកសារក្រោយម៉ោង ១៥ ដែលមិនអាចដោះស្រាយភ្លាមបាន នោះនឹងប្រគល់លទ្ធផលក្នុងថ្ងៃធ្វើការបន្ទាប់។ ក្នុងករណីត្រូវផ្ទៀងផ្ទាត់លក្ខខណ្ឌរៀបអាពាហ៍ពិពាហ៍របស់ភាគីទាំងពីរ បុរស និងស្ត្រី នោះរយៈពេលដោះស្រាយមិនលើសពី ០៥ ថ្ងៃធ្វើការ។

អនឡាញ៖ ភ្លាមក្នុងថ្ងៃទទួលសំណុំឯកសារ។ ក្នុងករណីទទួលសំណុំឯកសារក្រោយម៉ោង ១៥ ដែលមិនអាចដោះស្រាយភ្លាមបាន នោះនឹងប្រគល់លទ្ធផលក្នុងថ្ងៃធ្វើការបន្ទាប់។ ក្នុងករណីត្រូវផ្ទៀងផ្ទាត់លក្ខខណ្ឌរៀបអាពា ហ៍ពិ ពាហ៍របស់ភាគីទាំងពីរ បុរស និងស្ត្រី នោះរយៈពេលដោះស្រាយមិនលើសពី ០៥ ថ្ងៃធ្វើការ។